ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរ៉ែនិងថាមពល**

**អគ្គនាយកដ្ឋានធនធានរ៉ែ**

## បទបង្ហាញ

## ស្តីពី

# នីតិវិធីនៃកិច្ចដំណើរការក្នុងអនុញ្ញាតឲ្យនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ តាមប្រព័ន្ធបញ្ជរតែមួយជាតិរបស់ក្រសួងរ៉ែនិងថាមពល

សាលាជាតិគយ ,ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០២៤

លោក កែវ ទួត អគ្គនាយករង នៃអគ្គនាយកដ្ឋានធនធានរ៉ែ

Tel : 017 231 888

Email : tourtcabinet@gmail.com

# មាតិកា

**សេចក្តីផ្តើម**

**I.នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ**

**១.ការចុះឈ្មោះក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ**( Trader )

**២.ការនាំចេញផលិតផលរ៉ែ**

២.១ ការស្នើសុំគោលការណ៍កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ

២.២ ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ

**៣.ការនាំចេញសំណាករ៉ែ( លិខិតបញ្ជាក់សំណាករ៉ែ )**

**៤.ការផ្ទៀងផ្ទាត់លើសំណើ**( Verifier )

**៥.ការទូទាត់ទង់ប្រាក់លើសំណើ** ( Cashier )

**៦.ការត្រួតពិនិត្យឡើងវិញលើសំណើ** ( Reviewer )

**៧.ការសម្រេចលើសំណើ** ( Approver )

**II ការប្រើប្រាស់លិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឲ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ**

**III.លទ្ធផលនៃការអនុវត្ត និងអត្ថប្រយោជន៍នៃការចូលរួមប្រើប្រាស់ប្រព័ន្ធបញ្ជរតែមួយជាតិ**

# សេចក្តីផ្តើម

ប្រកាសលេខ៥៧៥ សហវ. ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តជំហានដំបូងប្រព័ន្ធបញ្ជរតែមួយជាតិ របស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

សេចក្តីណែនាំស្តីពីនីតិវិធីនៃកិច្ចដំណើរការក្នុងការអនុញ្ញាតឱ្យនាំចេញ ផលិតផលរ៉ែនិងសំណាករ៉ែ តាមប្រព័ន្ធបញ្ជរតែមួយជាតិ ដោយបានដាក់ឱ្យអនុវត្តជាផ្លូវការ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ ២០២៤កន្លងទៅថ្មីៗនេះ។

- **គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ**
- **វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ**
- **លិខិតបញ្ជាក់សំណាករ៉ែ**

# I.នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ

## ១.ការចុះឈ្មោះក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ ( Trader )

អ្នកនាំចេញ ឬបុគ្គល ដែលទទួលបានការអនុញ្ញាតពីក្រសួងរ៉ែនិងថាមពលត្រូវបំពេញបែបបទដូចខាងក្រោម៖

- ចុះឈ្មោះសុំបង្កើតគណនីចូលប្រើប្រាស់ប្រព័ន្ធ តាមរយៈគេហទំព័រ www.nsw.gov.kh ដោយភ្ជាប់នូវឯកសារពាក់ព័ន្ធ មានជាអាទិ៍៖
  - វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ( អាករលើតម្លៃបន្ថែម-អតប )
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនមានសុពលភាព
  - ឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិក។
- ក្រោយពីបានចុះឈ្មោះរួចហើយ ម្ចាស់គណនីត្រូវចូលប្រើប្រាស់ប្រព័ន្ធ តាមរយៈកូដសម្ងាត់ដែលទទួលបានពីប្រព័ន្ធ និងត្រូវរក្សាទុកឱ្យមានសុវត្ថិភាព ដើម្បីប្រើប្រាស់ប្រកបដោយស្មារតីទទួលខុសត្រូវ។

# I.នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ

## ២. ការនាំចេញផលិតផលរ៉ែ

### ២.១ ការស្នើសុំគោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ

ក្រោយពីបានចុះឈ្មោះស្នើសុំបង្កើតគណនីប្រើប្រាស់ប្រព័ន្ធ នៅក្នុងប្រព័ន្ធបញ្ជរតែមួយជាតិរួចរាល់ អ្នកនាំចេញដែលមានបំណងនាំចេញផលិតផលរ៉ែត្រូវដាក់ពាក្យស្នើសុំគោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ ដោយត្រូវបំពេញទិន្នន័យក្នុងប្រអប់ព័ត៌មាន និងភ្ជាប់ឯកសារនានាក្នុងទម្រង់អេឡិចត្រូនិចតាមរយៈតំណរភ្ជាប់ https://live.nsw.gov.kh ឬ គេហទំព័រ www.nsw.gov.khរបស់ប្រព័ន្ធបញ្ជរតែមួយជាតិដោយផ្ទាល់។ រំហូរនីតិវិធីនៃការដាក់ពាក្យស្នើសុំ និងពិនិត្យវាយតម្លៃអនុម័ត ត្រូវបានដំណើរការដូចដ្យាក្រាមខាងក្រោម៖

# I.នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ

## ២.១ ការស្នើសុំគោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ (ត)



## ២.១ ការស្នើសុំគោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ (ត)

ថិរវេលានៃការពិនិត្យវាយតម្លៃឆ្លើយតបលើសំណើសុំគោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែមានរយៈពេល ៥ថ្ងៃកន្លះ។ រយៈពេលខាងលើ គឺជារយៈពេល នៃដំណើការការងារក្នុងដែនសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល ពុំបូកបញ្ចូលរយៈពេលនៃការបង់ប្រាក់និងបញ្ចូលឯកសារទៅក្នុងប្រព័ន្ធដែលត្រូវអនុវត្តដោយអ្នកនាំចេញ។

# I.នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ

## ២.១ ការស្នើសុំគោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ (ត)

ក្នុងករណីដែលប្រព័ន្ធដំណើរការពុំទាន់បានរលូនឬពេញលេញ អ្នកនាំចេញផលិតផលរ៉ែ អាចៈ

- យកឯកសាររឹង (Hard Copy) មកដាក់ស្នើសុំនៅក្រសួងរ៉ែ និងថាមពល
- យកលិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញ ដែលចេញដោយក្រសួងរ៉ែនិងថាមពល ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិជំហានដំបូង និង
- ស្នើសុំមកក្រសួងរ៉ែ និងថាមពល ដើម្បីបោះពុម្ពលិខិតគោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញជាឯកសាររឹង (Hard Copy)។

## ២.២ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ

ក្រោយពីបានស្នើសុំគោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែរួចរាល់ អ្នកនាំចេញត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនៃចេញផលិតផលរ៉ែដោយត្រូវបំពេញទិន្នន័យក្នុងប្រអប់ព័ត៌មាន និងភ្ជាប់ឯកសារនានាក្នុងទម្រង់អេឡិចត្រូនិចតាមរយៈតំណរភ្ជាប់ https://live.nsw.gov.kh ឬ គេហទំព័រ www.nsw.gov.khរបស់ប្រព័ន្ធបញ្ជរតែមួយជាតិដោយផ្ទាល់។ រំហូរនីតិវិធីនៃការដាក់ដាក់ពាក្យស្នើសុំ និងពិនិត្យវាយតម្លៃអនុម័ត ត្រូវបានដំណើរការដូចដ្យាក្រាមខាងក្រោម៖

# ២.២ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ (ត)



## ២.២ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ (ត)

ថិរវេលានៃការពិនិត្យវាយតម្លៃឆ្លើយតបលើសំណើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែមានរយៈពេល ៣ថ្ងៃ។ រយៈពេលខាងលើ គឺជារយៈពេល នៃដំណើការការងារក្នុងដែនសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល ពុំបូកបញ្ចូលរយៈពេលនៃការបង់ប្រាក់និងបញ្ចូលឯកសារទៅក្នុងប្រព័ន្ធដែលត្រូវអនុវត្តដោយអ្នកនាំចេញ។

## ២.២ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ (ត)

ក្នុងករណីដែលប្រព័ន្ធដំណើរការពុំទាន់បានរលូនឬពេញលេញ អ្នកនាំចេញផលិតផលរ៉ែ អាចៈ

- យកឯកសាររឹង (Hard Copy) មកដាក់ស្នើសុំនៅក្រសួងរ៉ែ និងថាមពល
- យកលិខិតវិញ្ញាបនបត្របញ្ជាក់ការនាំចេញ ដែលចេញដោយក្រសួងរ៉ែ និងថាមពល ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិជំហានដំបូង និង
- ស្នើសុំមកក្រសួងរ៉ែ និងថាមពល ដើម្បីបោះពុម្ពវិញ្ញាបនបត្របញ្ជាក់ការនាំចេញជាឯកសាររឹង (Hard Copy)។

# I.នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ

## ៣.ការនាំចេញសំណាករ៉ែ (លិខិតបញ្ជាក់សំណាករ៉ែ)(ត)

ក្រោយពីបានចុះឈ្មោះស្នើសុំបង្កើតគណនីប្រើប្រាស់ប្រព័ន្ធ នៅក្នុងប្រព័ន្ធបញ្ជរតែមួយជាតិរួចរាល់ បុគ្គលដែលមានបំណងនាំចេញសំណាករ៉ែ ត្រូវដាក់ពាក្យស្នើសុំលិខិតបញ្ជាក់សំណាករ៉ែដោយត្រូវបំពេញទិន្នន័យក្នុងប្រអប់ព័ត៌មាន និងភ្ជាប់ឯកសារនានាក្នុងទម្រង់អេឡិចត្រូនិចតាមរយៈតំណរភ្ជាប់ https://live.nsw.gov.kh ឬ គេហទំព័រ www.nsw.gov.kh របស់ប្រព័ន្ធបញ្ជរតែមួយជាតិដោយផ្ទាល់។ រំហូរនីតិវិធីនៃការដាក់ដាក់ពាក្យស្នើសុំ និងពិនិត្យវាយតម្លៃអនុម័ត ត្រូវបានដំណើរការដូចដ្យាក្រាមខាងក្រោម៖

# I.នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ

## ៣.ការនាំចេញសំណាករ៉ែ (លិខិតបញ្ជាក់សំណាករ៉ែ)(ត)



# I.នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ

## ៣.ការនាំចេញសំណាករ៉ែ (លិខិតបញ្ជាក់សំណាករ៉ែ)(ត)

ចិរវេលា នៃការពិនិត្យវាយតម្លៃឆ្លើយតបលើសំណើសុំលិខិតបញ្ជាក់សំណាករ៉ែមានរយៈពេល ៣ថ្ងៃកន្លះ។ រយៈពេលខាងលើនេះ គឺជារយៈពេល នៃដំណើការការងារក្នុងដែនសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល ពុំបូកបញ្ចូលរយៈពេលនៃការបង់ប្រាក់និងបញ្ចូលឯកសារទៅក្នុងប្រព័ន្ធដែលត្រូវអនុវត្តដោយអ្នកនាំចេញ។

# I.នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ

## ៣.ការនាំចេញសំណាករ៉ែ (លិខិតបញ្ជាក់សំណាករ៉ែ)(ត)

ក្នុងករណីដែលប្រព័ន្ធដំណើរការពុំទាន់បានរលូនឬពេញលេញ បុគ្គលស្នើសុំ អាចៈ

- យកឯកសាររឹង (Hard Copy) មកដាក់ស្នើសុំនៅក្រសួងរ៉ែ និងថាមពល
- យកលិខិតបញ្ជាក់សំណាករ៉ែ ដែលចេញដោយក្រសួងរ៉ែ និងថាមពល ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការអនុវត្ត ប្រព័ន្ធបញ្ជរតែមួយជាតិជំហានដំបូង និង
- ស្នើសុំមកក្រសួងរ៉ែ និងថាមពល ដើម្បីបោះពុម្ពលិខិតបញ្ជាក់សំណាករ៉ែជាឯកសាររឹង (Hard Copy)។

# I.នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ

៤.ការផ្ទៀងផ្ទាត់លើសំណើ( Verifier )

៥.ការទូទាត់បង់ប្រាក់លើសំណើ ( Cashier )

៦.ការត្រួតពិនិត្យឡើងវិញលើសំណើ ( Reviewer )

៧.ការសម្រេចលើសំណើ ( Approver )

## ॥ ការប្រើប្រាស់លិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឲ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ

អ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ ត្រូវបញ្ចូលទិន្នន័យលេខលិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែព្រមទាំងទិន្នន័យចាំបាច់ផ្សេងទៀត នាពេលបំពេញប្រតិវេទន៍គយក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មគយ។

## III.លទ្ធផល និងអត្ថប្រយោជន៍នៃការចូលរួមប្រើប្រាស់ប្រព័ន្ធបញ្ជរតែមួយជាតិ

**លទ្ធផលនៃការអនុវត្ត៖**គិតចាប់ពីពេលដាក់ឱ្យដំណើរការជាផ្លូវការរហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤

- គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ៖

  ពាក្យស្នើសុំ១០៣ អនុម័តចំនួន ៩៤កូតា កំពុងដំណើរការចំនួន ៤ និងបដិសេធឬផ្ញើត្រលប់ចំនួន ៥

- វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ៖

  ពាក្យស្នើសុំមានចំនួន ១២ ៧៨៥ បានអនុម័តចំនួន ១២ ០៦៦ កំពុងដំណើរការចំនួន ៦៣៨ និងបដិសេធ ១

- លិខិតបញ្ជាក់សំណាករ៉ែ ៖

  ពាក្យស្នើសុំ ៩ពាក្យ បានអនុម័តចំនួន ៨ និងកំពុងដំណើរការពិនិត្យចំនួន ១

# III.លទ្ធផល និងអត្ថប្រយោជន៍នៃការចូលរួមប្រើប្រាស់ប្រព័ន្ធបញ្ជរតែមួយជាតិ

**អត្ថប្រយោជន៍៖**

- ចូលរួមក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល
- ជួយសម្រួលថេរវេលាក្នុងកាប្រតិបត្តិឯកសារ
- បង្កើនប្រសិទ្ធភាពនៃការងារ
- ជួយសម្រួលដល់ធុរកិច្ចក្នុងការបំពេញ និងការទទួលបានឯកសារអនុម័តរួច
- ពង្រឹងបាននូវសុចរិតភាពនៃការបម្រើសេវាសាធារណៈ

# សូមអរគុណ

លោក កែវ ធួត អគ្គនាយករង នៃអគ្គនាយកដ្ឋានធនធានរ៉ែ (Tel: 017 231 888)